**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៦០ **អយក.សជណ**

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ ២០១៣

## សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បណ្ឌិត និងថ្នាក់ម៉ាស្ទ័រ
## ទៅសិក្សានៅ The National Graduate Institute for Policy Studies (GRIPS)
## នៃប្រទេសជប៉ុនក្នុងឆ្នាំ ២០១៤

**យោង** : - *លិខិតលេខ ៦២៦៩ អស២.កបទ.សអ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*

## ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងដល់មន្ត្រីរាជការដែលកំពុងបម្រើការងារនៅតាមក្រសួង-ស្ថាប័ននានាថា សម្រាប់ឆ្នាំ២០១៤ ខាងមុខនេះ *The National Graduate Institute for Policy Studies (GRIPS)* ដែលឧបត្ថម្ភដោយក្រសួងអប់រំជប៉ុន នឹងផ្តល់អាហារូបករណ៍ដល់មន្ត្រីរាជការកម្ពុជា ឱ្យទៅបន្តការសិក្សា ថ្នាក់បណ្ឌិត និងថ្នាក់ម៉ាស្ទ័រ លើជំនាញផ្សេងៗ នៅប្រទេសជប៉ុនចាប់ពីខែតុលា ឆ្នាំ២០១៤ ។

ភាគីមិត្តរ៉ាប់រងថ្លៃសិក្សា-ផ្តល់ប្រាក់អាហារូបករណ៍-ការស្នាក់នៅ-ថ្លៃសំបុត្រយន្តហោះទៅ-មក និងថ្លៃផ្សេងៗទៀត ។

### I-លក្ខខណ្ឌនៃការចូលរួមជាបេក្ខជន

លក្ខខណ្ឌនៃការចូលរួមជាបេក្ខជនត្រូវបានកំណត់ទៅតាមមុខជំនាញផ្សេងៗគ្នាដែលសាមីជនអាចមើលនៅក្នុងគេហទំព័ររបស់**GRIPS**ដែលមានអាសយដ្ឋានhttp://www.grips.ac.jp/en/pstudents/admissions/ ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

## II-កម្មវិធីសិក្សាមាន :

១. Policy Analysis Program (Master's and Ph.D. Programs) ផុតកំណត់ទទួលពាក្យ១៤ វិច្ឆិកា២០១៣

២. Public Policy ( Master's program) ផុតកំណត់ទទួលពាក្យ ០៥ ធ្នូ ២០១៣

៣. Public Finance (Master's program) ផុតកំណត់ទទួលពាក្យ ២០ កុម្ភៈ ២០១៤

## III-កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ

បេក្ខជនដែលមានបំណងចង់ចូលរួមក្នុងវគ្គសិក្សាខាងលើត្រូវ Download ពាក្យសុំ និងបំពេញសំណុំឯកសារ ផ្សេងៗទៅតាមលក្ខខណ្ឌកំណត់របស់វគ្គសិក្សានៃមុខវិជ្ជានីមួយៗ រួចបញ្ជូនសំណុំឯកសារទាំងនោះទៅកាន់ ទីកន្លែង ដូចបានរៀបរាប់ក្នុងតារាងខាងលើតាមរយៈគេហទំព័ររបស់ **(GRIPS)** ដែលមានអាសយដ្ឋាន http://www.grips.ac.jp/en/pstudents/admissions/ ។ ចំពោះពត៌មានពីការចុះឈ្មោះបេក្ខជនអាចទាក់ទងជាមួយ **(GRIPS)** តាមរយៈអ៊ីមែល admissions@grips.ac.jp ។

**ត.ប. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អគ្គនាយក**

ថោង បូរ៉ាន់

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ស្ថានទូតជប៉ុននៅភ្នំពេញ

"ដើម្បីជូនជ្រាប"

-គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-អង្គភាពក្រោមឱវាទទីស្តីការក្រសួង អប់រំ យុវជន និងកីឡា

-គ្រប់គ្រឹះស្ថានឧត្តមសិក្សា

"ដើម្បីសូមជួយផ្សព្វផ្សាយ"

-កាលប្បវត្តិ-ឯកសារ នា.ទ.វ.អ